ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៧៥ សប្តាហ៍ទី ២ ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៧-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩២៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គីម យ៉ុងសឹក (KIM YOUNG SEOK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងសេអ៊ូលសាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា គីម តារា (KIM DARA) ៧៤២១

២-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៥៣ ស្តីពីការតាំងស៊ប់មន្ត្រីរាជការស៊ីវិល ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០៧ រូប ៧៤២២

៣-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៥៤ ស្តីពីការដាក់លោក លន់ សុជាតិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០០៩ តទៅ ៧៤២៤

៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៥៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ០៣ រូប ៧៤២៥

៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៥៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ធីរៈយុទ្ធ ពោធិអាត (VEERAYUTHI PHOTHI-AT) ជនជាតិថៃឡង់ដ៍ សញ្ជាតិថៃឡង់ដ៍ កើតនៅក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ៧៤២៦

៨-១០-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/១០០៩/៩៦០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ូ ជាង (Shu Jiang) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហ៊ូណាន ប្រទេសចិន ៧៤២៧

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

៩-១០-២០០៩ -អនុក្រឹត្យលេខ ១៦៦ អនក្រ.បក ស្តីពីការផ្ទេរដីទំហំ ៣៥០ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ស្ថិតនៅក្នុងឃុំត្រស់ និង ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ៧៤២៨

៩-១០-២០០៩ -អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ស្តីពីការធ្វើអនុបយោគ ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋសម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅក្នុងឃុំត្រស់និងឃុំគគីរ ស្រុករមាសហែកខេត្តស្វាយរៀង ៧៤៣២

០៩-១០-២០០៩ -អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ស្តីពីការធ្វើអនុបយោគទីតាំងដីទំហំ ៧៧.៨២ ហិកតា នៅតំបន់ភ្នំពេញ ៧៤១

០៩-១០-២០០៩ -អនុក្រឹត្យលេខ ១៦៩ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ៧៤១

០៦-១០-២០០៩ -អនុក្រឹត្យលេខ ១៥០២ អនក្រ.តត ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ៧៤

០៦-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៤

០៧-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៤

០៧-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៥ អនក្រ.តត ស្តីពីការអនុវត្តវិន័យនាយនគរបាលជាតិ ៧៤

០៧-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៤

០៧-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៤

០៧-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៤

០៨-១០-២០០៩ -អនុក្រឹត្យលេខ ១៥០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤

០៨-១០-២០០៩ -អនុក្រឹត្យលេខ ១៥១០ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៧៤

០៨-១០-២០០៩ -អនុក្រឹត្យលេខ ១៥១១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៤

០៨-១០-២០០៩ -អនុក្រឹត្យលេខ ១៥១២ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៧៤

០៩-១០-២០០៩ -អនុក្រឹត្យលេខ ១៥១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤

២. សេចក្តីសម្រេច

០៧-១០-២០០៩ -សេចក្តីសម្រេចលេខ ៥៩ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និង សេនាសនៈ វត្ត ព្រៃអង្គរក្នុង ស្ថិតក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ៧៤

III. ការងារបណ្តាក្រសួង

១. ធនាគារជាតិ នៃ កម្ពុជា

០៩-៩-២០០៩ -ប្រកាសលេខ ធ ៧.០៩-២១៣ ប្រក ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ៧៤

១៥-៩-២០០៩ -ប្រកាសលេខ ធ ៧.០៩-២១៦ ប្រក ស្តីពីការផ្តល់របាយការណ៍ឥណទានធំ និង ពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ ៧៤

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

០៥-១០-២០០៩-ប្រកាសលេខ ២០៦ បទ.ប្រក ស្តីអំពីការតភ្ជាប់បណ្តាញទូរគមនាគមន៍ ៧៤

៣_ឯកសារស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៥៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាមេរិខិន ខេសធើន អិចផត អេនធើប្រាយ ៧៥០២

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៥៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ភី.ធី.ធី.ត្រេឌីង ៧៥០៤

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សុខ សុខា ត្រាវែល ៧៥០៦

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ចេចហ្គាន (ខេមបូឌា) អយល៍ អេន ហ្គាស អិចផ្លូរេសិន ៧៥០៨

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហេច លាភ ឌីវេឡុបមេន អ៊ីមផត អិចផត ខូ អិលធីឌី ៧៥១០

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ.អេស.អិម.ស៊ី អ៊ែតធើថាយស៊ីង ៧៥១២

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ថេត បាយអូ គ្លូបិល ធើលឌ៍ ៧៥១៤

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ ប៊ី ហ្វាម៉ា ៧៥១៦

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៦៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សៃណ ស្រេង អ៊ីមផត អិចផត ៧៥១៨

០៩-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៨៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ឌីហ្សាញ ឌី អេ យូ គ្រុប ខូ អិលធីឌី ៧៥២០

១៣-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៨៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មង្គល អ៊ីមនិច ខូ អិលធីឌី ៧៥២១

១៣-០១-២០០៩ -លិខិតបញ្ជាក់លេខ ០១៨៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឧត្តមចន្លេនៈ គ្រុប ខូ អិលធីឌី ៧៥២៣

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម យ៉ុងសឹក** (KIM YOUNG SEOK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៧៤ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម តារា** (KIM DARA)។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧.០៩០៩.៩៤៤

លេខៈ ៧៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០៧ រូប ដូចមានរាយនាមខាងក្រោម :

ល.រ	នាមនិងគោត្តនាម	ភេទ	ឋានន្តរស័ក្តិនិងថ្នាក់	ថ្ងៃខែឆ្នាំតាំងស៊ប់
១	ហ៊ុន ម៉ានី	ប	អនុមន្ត្រី ថ្នាក់លេខ១៣	០១-០៣-២០០៩
[illegible]	អ៊ុក ស៊ីដែន	ប	អនុមន្ត្រី ថ្នាក់លេខ១៣	០១-០៣-២០០៩
៣	ពេជ អភិរៈ	ប	អនុមន្ត្រី ថ្នាក់លេខ១៣	០១-០៣-២០០៩

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL
ព្រះបរមរាជវាំង

៤	ហុង វណ្ណារ៉ា	ប	អនុមន្ត្រី ថ្នាក់លេខ១៤	០១-០៤-២០០៩
៥	ចៅ ឡាយ	ប	អនុមន្ត្រី ថ្នាក់លេខ១៤	០១-០៤-២០០៩
៦	ស៊ុយ រីណា	ស	អនុមន្ត្រី ថ្នាក់លេខ១៤	០១-០៤-២០០៩
៧	ឆឹង ស៊ីមន	ស	អនុមន្ត្រី ថ្នាក់លេខ១៤	០១-០៤-២០០៩

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣រល.០៩១០.៩៧០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៩

លេខ:៨៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្ រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់លោក **លន់ សុជាតិ** ឧត្តមមន្ត្រី ថ្នាក់លេខ៥ នៃទីស្តីការគណៈរដ្ឋមន្ត្រី អោយចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចាប់ពី ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តទៅ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.រ៧.០៩១០.៩៧១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៩

លេខ:៨៩៦ ច.ល

ជូនចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/១០០៩/៩៥៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

១- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម លាង** អត្តលេខ ០០៥១៨២

២- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

- លោកបណ្ឌិត **ថេង ចំនួនសង្វារ**

៣- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

- លោក **នួន ដានីញ៉ែល**

៣៣.០៩១០.៩៧៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែ តុលា ឆ្នាំ ២០០៩

លេខ:៨៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ទីរៈយុទ្ធ ពោធិអាត** (VEERAYUTHI PHOTHI-AT) ជនជាតិថៃឡង់ដ៍ សញ្ជាតិថៃឡង់ដ៍ កើតថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៥១ នៅក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៩

៣រ.ល. ០៩១០.៩៧៦

លេខៈ ៩០៧ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០០៩
[illegible]រាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៩/៩៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ លោក **ស៊ូ ជាង** (Shu Jiang) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៣ នៅខេត្តហ៊ូណាន ប្រទេសចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ៧.០៩១០.៩៧៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៩

លេខៈ ៩០០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩
ទីស្តីការគណៈរដ្ឋមន្ត្រី / រាជរដ្ឋាភិបាល
ស៊ុន ជិនគេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៦ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរដីទំហំ ៣៥០ (បីរយហាសិប) ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពី សម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូពាមជាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានផ្ទេរដីទំហំ ៣៥០ (បីរយហាសិប) ហិកតា ចេញពីទំហំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អានម៉ាឌីគ្រុប ស្ថិតនៅក្នុងឃុំគ្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកានៃប្រពន្ធ័កូអ័រដោណេ UTM, Zone 48 N , Datum Indian 1960 : ពីចំណុច ១ ដល់ចំណុច៦ និងពីចំណុច ៧ ដល់ចំណុច១០ : ១ (៥៩២៩៤៥, ១២៧៤៣៧៤), ២ (៥៩២៤៥៥, ១២៧៤៤៥០), ៣ (៥៩១៩៦៧, ១២៧៤២៥២) , ៤ (៥៩០៦១០, ១២៧៣៤២៥), ៥ (៥៩០០៨០, ១២៧២៩៧០), ៦ (៥៩០១៤២, ១២៧១៣៧២), ៧ (៥៩៤៥៨៨, ១២៦៩៤៩៥), ៨ (៥៩៥០៥០,១២៦៩១៣៥), ៩ (៥៩៥៤៩៣, ១២៦៩៣១០), ១០ (៥៩៥០២០, ១២៧០២៤៦) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋជូនអាជ្ញាធរកាន់កាប់ដីរដ្ឋខេត្តស្វាយរៀង ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋទំហំ ៣៥០ (បីរយហាសិប) ហិកតា ដូចមានចែងក្នុងមាត្រា១នៃអនុក្រឹត្យនេះ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច តាមនីតិវិធីច្បាប់ជាធរមាន ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី

រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ក្រុមហ៊ុន អាន ម៉ាឌី គ្រុប*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*



ប្លង់បង្ហាញទីតាំង នៃការផ្ទេរដីទំហំ ៣៥០ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អាន ម៉ារី គ្រុប

ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ១៦៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

មាត្រដ្ឋាន 1:40,000

តារាងនិយាមការ

Projection Indian 1960 UTM zone 48N

Points_ID	Easting (m)	Northing (m)
1	592945	1274374
2	592455	1274450
3	591967	1274252
4	590610	1273425
5	590080	1272970
6	590142	1271372
7	594588	1269495
8	595050	1269135
9	595493	1269310
10	595020	1270246

សញ្ញាសំគាល់

បង្គោលព្រំដី

ព្រំប្រទល់ប្រទេស

ព្រំប្រទល់ឃុំ

ទីតាំងដី នៃអនុក្រឹត្យ

ក = ៣០០.០០ហិកតា

ខ = ៥០.០០ហិកតា

ក្រឡាផ្ទៃដីសរុប: ក + ខ = ៣៥០,០០ហិកតា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ១៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើអនុបយោគ ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានផ្ទេរដីព្រៃរេចរិលទំហំ ៤៧៤,៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកានៃប្រពន្ធ័កូអ័រដោណេ UTM, Zone 48 N Datum Indian 1960 : ពីចំណុច ១ ដល់ចំណុច ១៧ និងពីចំណុច ១៨ ដល់ចំណុច ២៦ :

១ (៥៩២៩៤៥, ១២៧៤៣៧៤), ២ (៥៩៣១០៦, ១២៧៥៤៥៥), ៣ (៥៩២០៤១, ១២៧៦៤០៣), ៤ (៥៩២៩៣៨, ១២៧៧៨៥២), ៥ (៥៩២៤១៥, ១២៧៧៨៨៤), ៦ (៥៩២៣៨៧, ១២៧៨១៣០), ៧ (៥៩២១៦០, ១២៧៧៩៨៦), ៨ (៥៩១៣៣៤, ១២៧៦៣៧៧), ៩ (៥៩០៨០២, ១២៧៦៣០៤), ១០ (៥៩០២២៤, ១២៧៥៩៦២), ១១ (៥៨៩៦៧៤, ១២៧៥៦២៤), ១២ (៥៨៩៦៧៤, ១២៧៥៣៥៤), ១៣ (៥៩០៧៣០, ១២៧៥៣៥៣), ១៤ (៥៩១០៥០, ១២៧៥៦៨៧), ១៥ (៥៩១១៥៩, ១២៧៥៧១១), ១៦ (៥៩២០៥០, ១២៧៥៣១៦), ១៧ (៥៩២៤៥៥, ១២៧៤៤៥០) ១៨ (៥៩០០៨០, ១២៧២៩៧០), ១៩ (៥៩០០២៩, ១២៧២៦៤១), ២០ (៥៨៩៨០៤, ១២៧១១៨៦), ២១ (៥៨៩៨៣៩, ១២៧១០២៨), ២២ (៥៩០០១៩, ១២៧០៨៩៥), ២៣ (៥៩០៦៥១, ១២៧០៨៤២), ២៤ (៥៩០៤៨២, ១២៧១១៣០), ២៥ (៥៩០១៥០, ១២៧១១៧៦), ២៦ (៥៩០១៤២, ១២៧១៣៧២) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៤៧៤,៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

មាត្រា ៣.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ជូនអាជ្ញាធរកាន់កាប់ដីរដ្ឋ ខេត្តស្វាយរៀង ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋទំហំ ៤៧៤,៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច តាមនីតិវិធីច្បាប់ជាធរមាន។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ* ✓



តារាងនិយាមការ

Projection Indian 1960 UTM zone 48N

Points_ID	Easting (m)	Northing (m)
1	592945	1274374
2	593106	1275455
3	592041	1276403
4	592938	1277852
5	592415	1277884
6	592387	1278130
7	592160	1277986
8	591334	1276377
9	590802	1276304
10	590224	1275962
11	589674	1275624
12	589674	1275354
13	590730	1275353
14	591050	1275687
15	591159	1275711
16	592050	1275316
17	592455	1274450
18	590080	1272970
19	590029	1272641
20	589804	1271186
21	589839	1271028
22	590019	1270895
23	590651	1270842
24	590482	1271130
25	590150	1271176
26	590142	1271372

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគទីតាំងដីទំហំ ៧៧.៨២ ហិតា នៅតំបន់ភ្នំពោន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-លិខិតលេខ ២៦៩៨ /០៨ កអក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ផែនទីបែងចែកតំបន់អភិវឌ្ឍន៍ភ្នំពោន របស់គណៈកម្មការអន្តរក្រសួង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ ។

សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដីទំហំ ៧៧.៨២ ហិតា ស្ថិតនៅតំបន់ភ្នំពោន ក្នុង

ភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ដើម្បីធ្វើការអភិរក្ស និង អភិវឌ្ឍន៍ក្រោមល័ក្ខខ័ណ្ឌ ជួលរយៈពេលវែង។

មាត្រា ២.-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុង មាត្រា១ ត្រូវស្ថិតនៅក្រោមការចាត់ចែងបន្តតាមនីតិវិធីដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និង សាលាខេត្តពាក់ព័ន្ធ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង អភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ..១៦៨....អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរគ្រប់គ្រងគណនី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាស សាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដើម្បីចំណាយលើការងារបំពាក់គ្រឿងបរិក្ខារ និងតុបតែងលម្អអគារទីស្តីការនាយករដ្ឋមន្ត្រី និងមជ្ឈមណ្ឌលសន្និសីទអន្តរជាតិ មានទឹកប្រាក់ចំនួន **១០,០០០,០០០ ដុល្លារអាមេរិក** (ដប់លានដុល្លារអាមេរិក) ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ដើម្បីជូនជ្រាប)
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៥០២.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានបញ្ចប់ភារកិច្ចលោក **គឹម ពិសិដ្ឋ** ពីជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ... រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥០៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ **ឯកឧត្តម អ៊ុច សេរីវិសុទ្ធ ពីឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ ១០ ទៅ វរមន្ត្រីថ្នាក់លេខ ១០** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ [illegible] ០៧ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ២
រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥០៤.អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
របស់
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហាន នាយទាហានរង និងពលទាហាន ចំណុះបញ្ជាវិស្វកម្មកងទ័ពជើងគោក ចំនួន **៧៣** រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ធ្វើថ្នល់ ស្ពាន ដោះបំផ្លាញមីនគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅតាមបណ្តោយព្រំដែនកម្ពុជា - ថៃ កន្លងមក ដូចមានរាយនាមខាងក្រោម ÷

១	វរសេនីយ៍ទោ	ឈោច ណារី	០១៧៦៧០	នាយរងផ្នែកបញ្ជូនសារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើ
២	វរសេនីយ៍ត្រី	ហង្ស សាខន	០២៧១៨១	មេរង.កង ស្ពាបនាផ្លូវ ថ្នល់ លេខ៧៦ បញ្ជាការដ្ឋានវិ
៣	វរសេនីយ៍ត្រី	ផាន់ ផារ៉ា	០០៩២៧៤	នាយរងផ្នែកចលនុប្បត្តម្ភ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើង
៤	វរសេនីយ៍ត្រី	កែវ សុផល	០១៧៥៦៥	នាយរងផ្នែកសំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើ
៥	វរសេនីយ៍ត្រី	ហាន ចេច	០២៧១៧០	នាយផ្នែកយានដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើង
៦	វរសេនីយ៍ត្រី	យឹម ប៊ុនណារ៉ុម	០២០៨១៩	នាយរងផ្នែកហ្វឹកហ្វឺន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើង
៧	វរសេនីយ៍ត្រី	ខឹម វណ្ណារ៉ា	០០៣៤៤២	នាយរងផ្នែកបច្ចេកទេស បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើង
៨	វរសេនីយ៍ត្រី	ម៉ើ ប៊ុនឡឿន	០១៧៦២០	មេរង.កង ស្ថាបនាសំណង់អាគារ និងវត្ថុរាំង លេខ

៩	វរសេនីយ៍ត្រី	ចាន់ ធយន	០១១៣៦១	នាយរងផ្នែកបច្ចេកទេស បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក
១០	វរសេនីយ៍ត្រី	សាង យឿន	០២៧២៣៥	មេរង.កង ស្ថាបនាសំណង់អាគារ និងវត្ថុរាំង លេខ ៧៨
១១	វរសេនីយ៍ត្រី	គោគ សុទ្ធិ	០១៧៥៩៧	នាយផ្នែកឃ្លាំង បញ្ជាការដ្ឋានវិស្វកម្ម
១២	វរសេនីយ៍ត្រី	សៅ សីហា	០៤៣៤៥៣	នាយរងផ្នែកប្រតិបត្តិការសឹក បញ្ជាការដ្ឋានវិស្វកម្ម
១៣	វរសេនីយ៍ត្រី	ពូន ចំណាប់	០៤៣៤៥០	នាយរងផ្នែកសំណង់យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម
១៤	អនុសេនីយ៍ឯក	ហែម ម៉ុនធីម	០៣៣១៨១	នាយរងផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម
១៥	អនុសេនីយ៍ឯក	ម៉ៅ កែវ	០០៤៥០០	ជំនួយការឃោសនាពត៌មាន បញ្ជាការដ្ឋានវិស្វកម្ម
១៦	អនុសេនីយ៍ឯក	គង់ សារិ	០៥១៣៣០	ជំនួយការឃោសនាពត៌មាន បញ្ជាការដ្ឋានវិស្វកម្ម
១៧	អនុសេនីយ៍ឯក	ម៉ក់ កល្យាន	០៥៣៦៩៩	ជំនួយការឃោសនាពត៌មាន បញ្ជាការដ្ឋានវិស្វកម្ម
១៨	អនុសេនីយ៍ឯក	អ៊ុន សិរីវឌ្ឍនា	០៤៤២៣៣	ជំនួយការបច្ចេកទេស បញ្ជាការដ្ឋានវិស្វកម្ម
១៩	អនុសេនីយ៍ឯក	គង់ សំអាត	០៦៩៤៣៧	ជំនួយការបុគ្គលិក បញ្ជាការដ្ឋានវិស្វកម្ម
២០	អនុសេនីយ៍ឯក	អ៊ុំ វ៉ាន	២២១៦៩៦	ជំនួយការសំណង់យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម
២១	អនុសេនីយ៍ឯក	កែវ សុផល	០២៧១៧៨	មេ.កងធំ I កងស្ថាបនាស្ពាន លូ លេខ ៧៧
២២	អនុសេនីយ៍ឯក	ម៉ុន ថាវី	០៤៩៣៦៥	ជំនួយការហិរញ្ញវត្ថុ កងស្ថាបនាស្ពាន លូ លេខ ៧៧
២៣	អនុសេនីយ៍ឯក	ឆោម សារ៉ាម	០១៧៦១៤	មេ.កងធំ I កងស្ថាបនាសំណង់អាគារនិងវត្ថុរាំង លេខ ៧៨
២៤	អនុសេនីយ៍ឯក	អ៊ុច ហ៊ង	២២១៧៣៥	ជំនួយការចលនូបត្ថម្ភ បញ្ជាការដ្ឋានវិស្វកម្ម
២៥	អនុសេនីយ៍ឯក	ឆោង រតនៈ	០២៧១៨៤	ជំនួយការបុគ្គលិក បញ្ជាការដ្ឋានវិស្វកម្ម
២៦	អនុសេនីយ៍ឯក	ម៉ុក គឹមស្រ៊ាន់	២២២២៤៣	ជំនួយការឃោសនាពត៌មាន បញ្ជាការដ្ឋានវិស្វកម្ម
២៧	អនុសេនីយ៍ឯក	សេង សាវ៉េត	០៣០៦៤៩	ជំនួយការហិរញ្ញវត្ថុ កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
២៨	អនុសេនីយ៍ឯក	ឆៅត ពឿយ	០១០៨៣៨	មេ.កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
២៩	អនុសេនីយ៍ឯក	ឆិត្យ ឈុំ	០១៧៦០៨	ជំនួយការបច្ចេកទេស បញ្ជាការដ្ឋានវិស្វកម្ម
៣០	អនុសេនីយ៍ឯក	សន រ៉ា	០២៧២១២	នាយរងផ្នែកបញ្ជូនសារ បញ្ជាការដ្ឋានវិស្វកម្ម
៣១	អនុសេនីយ៍ឯក	សិរិត សុខលី	០២៧០៨១	ជំនួយការសំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម
៣២	អនុសេនីយ៍ឯក	ឈឹម ផង់	០១០៨៤២	មេ.កងធំ II កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
៣៣	អនុសេនីយ៍ឯក	ហ៊ាង ធី	០២៧១៥២	នាយរងផ្នែកសំណង់យុទ្ធសាស្ត្រ បញ្ជាការដ្ឋានវិស្វកម្ម
៣៤	អនុសេនីយ៍ឯក	កែវ គឹមឆែន	០៣៩៥៥២	ជំនួយការចលនូបត្ថម្ភ បញ្ជាការដ្ឋានវិស្វកម្ម
៣៥	អនុសេនីយ៍ឯក	ញឹម សាខន	០២៧១៨០	ជំនួយការរថយន្ត កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៣៦	អនុសេនីយ៍ឯក	ឌុន សុផាន	០៣៧៣៦៨	ជំនួយការគ្រឿងចក្រ កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៣៧	អនុសេនីយ៍ឯក	សុខ ដារ៉ា	១៤៩៩៧៩	ជំនួយការ លេខាធិការដ្ឋាន យោធភូមិភាគពិសេស
៣៨	អនុសេនីយ៍ទោ	សឹង ទ្រី	០១៦២៤១	មេ.កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
៣៩	អនុសេនីយ៍ទោ	ថ៊ែន ឈឿប	០៣៩៥៣៣	ជំនួយការយានដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម
៤០	អនុសេនីយ៍ទោ	ឆែម អាត	០៤៧៥៨៧	ជំនួយការប្រតិបត្តិការសឹក បញ្ជាការដ្ឋានវិស្វកម្ម

៤១	អនុសេនីយ៍ទោ	ជា គាជ	០៧១៧៤៧	ជំនួយការប្រតិបត្តិការសឹក បញ្ជាការដ្ឋានវិស្វកម្ម
៤២	អនុសេនីយ៍ទោ	គង់ ឆន	០៣០៦៦៤	មេរង.កងធំ II កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
៤៣	អនុសេនីយ៍ទោ	កែវ សាន់ឌី	០២៧១៨៣	មេ.កងធំ III កងស្ថាបនាសំណង់អាគារនិងវត្ថុរាំង លេខ ៧៨
៤៤	អនុសេនីយ៍ទោ	ម៉ុល សុធា	០២៤៤៤៧	ជំនួយការសំណង់អាគារ បញ្ជាការដ្ឋានវិស្វកម្ម
៤៥	អនុសេនីយ៍ទោ	សុខា ណារ៉ូ	២៣១៥៥៤	ជំនួយការប្រតិបត្តិការសឹក បញ្ជាការដ្ឋានវិស្វកម្ម
៤៦	អនុសេនីយ៍ទោ	សុខ សារឿន	០៩៣៣៦១	ជំនួយការរថយន្ត កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៤៧	អនុសេនីយ៍ត្រី	កេត អារុណ	១៦៦៥១០	ជំនួយការបុគ្គលិក បញ្ជាការដ្ឋានវិស្វកម្ម
៤៨	អនុសេនីយ៍ត្រី	ជា កុសល	០៣០៦៧២	មេរង.កងធំ III កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦១
៤៩	អនុសេនីយ៍ត្រី	អ៊ែន រិន	០៣៩៩៤៦	មេ.កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥០	អនុសេនីយ៍ត្រី	សេង សុផាន	២២២៤៣៧	មេ.កងតូច III កងធំ IV កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥១	អនុសេនីយ៍ត្រី	ស៊ូ ម៉ុត្រា	០៣៩៩៣២	មេ.កងតូច III កងធំ IV កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥២	អនុសេនីយ៍ត្រី	សួស មុណា	០៣៩៩៣៨	មេ.កងតូច II កងធំ IV កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៣	អនុសេនីយ៍ត្រី	គង់ សារ៉ាត់	០៣៩៩៣៦	មេ.កងតូច III កងធំ III កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៤	អនុសេនីយ៍ត្រី	អ៊ុំ ចាន់ធី	០៤៩២៨៣	មេ.កងតូច II កងធំ III កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៥	ព្រិន្ទបាលឯក	ឆាំ ម៉ី	០៥៣៧៣២	មេរង.កងតូច I កងធំ II កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៦	ព្រិន្ទបាលឯក	សុខ ស៊ីណារិន	១៦០១៦៧	មេ.កងតូច I កងធំ III កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៧	ព្រិន្ទបាលឯក	មាស ឡាញ់	០៤៩៣០៨	មេរង.កងតូច II កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៨	ព្រិន្ទបាលឯក	ថោង ជឿន	២១៤៥៧២	មេរង.កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៥៩	ព្រិន្ទបាលឯក	សែម សុផា	២២១៦៣៧	មេក្រុម I .កងតូច I កងធំ IV កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៦០	ព្រិន្ទបាលឯក	តែម រិទ្ធ	០៥៩៤៦៥	ជំនួយការស្ថាបនាផ្លូវ ថ្នល់ កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៦១	ព្រិន្ទបាលឯក	ហ៊ា ឃួន	១៦៧០៣២	មេក្រុម II .កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៦២	ព្រិន្ទបាលឯក	ហាស់ ថាវរ៉ូ	២២១៦៨៦	មេក្រុម I .កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦
៦៣	ព្រិន្ទបាលឯក	សែម សាម៉ុន	១៣២៦០៦	មេក្រុម II .កងតូច I កងធំ I កងស្ថាបនាស្ពាន លូ លេខ ៧៧
៦៤	ព្រិន្ទបាលឯក	ទឹម សុជាតិ	០៧២០៧៨	ជំនួយការ កុំព្យូទ័រ លេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម
៦៥	ព្រិន្ទបាលទោ	ឆាំ ពោត	០៨០៤៧៧	មេក្រុមរង III .កងតូច II កងធំ II កងស្ថាបនាផ្លូវ ថ្នល់ លេខ៧៦
៦៦	ព្រិន្ទបាលទោ	អាត ចំរើន	១៧៦៦៩៣	មេក្រុមរង I .កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ៧៦
៦៧	ពលបាលឯក	អ៊ុច ភក្តដា	១៧៧៨៩៤	មេក្រុម I .កងតូច I កងអនុសេនាធំស្ពានចល័ត បញ្ជាការដ្ឋានវិស្វកម្ម
៦៨	ពលបាលឯក	ពាក្យ សារ៉ាយ	០៧៥៨១៦	ជំនួយការ កុំព្យូទ័រ ផ្នែកលេខាធិការដ្ឋាន បញ្ជាការដ្ឋានវិស្វកម្ម
៦៩	ពលបាលទោ	ជួម ផល	០៨០៤៥៣	ពលទាហាន ក្រុម II កងតូច I កងធំ I កងអនុសេនាធំផ្គត់ផ្គង់ទឹក
៧០	ពលបាលត្រី	ណេង សំណាង	១០៥៧១៣	នាយពួក I ក្រុម I .កងតូច I កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ៧៦
៧១	ពលបាលត្រី	ស្រី សុខា	២២១៧៣៦	នាយពួក III ក្រុម I .កងតូច III កងធំ I កងស្ថាបនាផ្លូវ ថ្នល់ លេខ ៧៦

៧២	ពលបាលត្រី	**ឡូច ម៉ោច**	២២២៧២៩	នាយពូក៖ ក្រុម៖ .កងតូច ៣៖ កងធំ ៣ កងស្លាបនាផ្លូវ ថ្នល់ លេខ ៧៦១
៧៣	នាយឯក	**ជុំ សាយន**	១១៤៩៧១	ពលទាហានក្រុម៖ .កងតូច៖ កងធំ ៣ កងស្លាបនាស្ពាន លូ លេខ៧៧

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការអនុវត្តវិន័យនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១ : ត្រូវបានអនុវត្តវិន័យលោកស្រីវរសេនីយ៍ឯក **ជា រដ្ឋា** អត្តលេខ ៩៤៨៨៨ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដោយរូបភាពដកហូតឋានន្តរសក្តិ និងបណ្តេញចេញផុតពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ និងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ ត.ក . ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥០៧. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- លោក ម៉ាក់ សួជរី មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោក ទៀង វុធ្ឍី មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ៤
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៥០៧ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

សម្រេច

មាត្រា ១ : តែងតាំងជំនួយការឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម :

១- លោក **លី សារី**

២- លោក **ឈាង តារា** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៥០៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.—

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន០៥រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយកសាងអគារសិក្សា និងសមិទ្ធផលនានា ក្នុងវិស័យអប់រំ នៅខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

-ឧត្តមសេនីយ៍ MARK M. SCHNABEL មេបញ្ជាការកងទ័ពម៉ារីនប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

១-លោក JONATHAN C. HERWIG ទីប្រឹក្សាបច្ចេកទេសសំណង់ក្រុមហ៊ុន NEW HORIZON

២-លោក JOHN R. TROHA ទីប្រឹក្សាបច្ចេកទេសសំណង់ក្រុមហ៊ុន NEW HORIZON

៣-លោក HIEU PHAM អ្នកធ្វើគំរោងកិច្ចការស៊ីវិលបញ្ជាការដ្ឋានសហរដ្ឋអាមេរិក នៅប៉ាស៊ីហ្វិក

៤-លោក CHAD WITHERELL អ្នកធ្វើគំរោងកិច្ចការស៊ីវិលបញ្ជាការដ្ឋានសហរដ្ឋអាមេរិក នៅប៉ាស៊ីហ្វិក

មាត្រា២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន-រដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤០៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ២៣ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាង សមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងសមិទ្ធផលផ្សេងៗជាច្រើន នៅ**វត្តពោធិខង** និង**វត្តចាក់តាង** ស្ថិតក្នុងឃុំកញ្ជៀច ស្រុកកញ្ជៀច ខេត្តព្រៃវែង ដែលមានរាយនាមដូចខាងក្រោម :

ក~ មេដាយមាសស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :

១- លោក **យឹម សំរឹទ្ធហៃ** ប្រធានមូលដ្ឋានចំការកៅស៊ូជុប ថវិកាចំនួន ១១.៣៥០ ដុល្លារ

២-លោក **ឈឹម ដារុទ្ធ** ជំនួការផ្ទាល់ អគ្គស្នងការរងនគរបាលជាតិ ថវិកាចំនួន ១១.៣០០ ដុល្លារ

៣-លោក **ឃុន គឹមហ៊ាន** នាយផ្នែកហិរញ្ញវត្ថុ ការិយាល័យទី៥ យោធា ថវិកាចំនួន ១១.៣០០ ដុល្លារ

ខ~ មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :

១-លោក **ម៉ក់ ភាណេន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៥.៣០០ ដុល្លារ

២- ឧបាសក **ឡេង គឹមលី** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៥.២១០ ដុល្លារ

៣- ឧបាសិកា **ហោ ចន** សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ៥.២០០ ដុល្លារ

៤- ឧបាសក **ពុជ ស៊ីម** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៥.១០៣ ដុល្លារ

៥- ឧបាសិកា ស៊ី	ហៀក	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន	៥.១០៣ ដុល្លារ
៦- លោក រ៉ូខ	អៀង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៥.១០០ ដុល្លារ
៧- លោក ស៊ុយ	ម៉ោឈិន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៥.១០០ ដុល្លារ
៨- លោក ម៉ិន	រតនា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៥.១០០ ដុល្លារ
៩- លោក ចាំង	ហ៊ឿង	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន	៥.០០០ ដុល្លារ

គ- មេដាយសេវាជាតិ ចំនួន ១១ គ្រឿង ផ្តល់ជូន :

១- លោក ហុង	ឈាង	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន	៤.១០០ ដុល្លារ
២- លោក អាំ	ហាប	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន	៣.៥០០ ដុល្លារ
៣- លោក ហ៊ូ	ហ៊ឹម	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន	៣.១០០ ដុល្លារ
៤- ឧបាសិកា មាស	ឆៀ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	៣.១០០ ដុល្លារ
៥- លោក ឌឹម	ថុល	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	២.៧០០ ដុល្លារ
៦- លោក អ៊ិង	ម្ងួត	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	២.២០០ ដុល្លារ
៧- លោកស្រី ឌុក	សុខី	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន	២.១១០ ដុល្លារ
៨- លោក ហោ	សេងហ៊ាន	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកាចំនួន	២.១០០ ដុល្លារ
៩- លោក មាស	សុត	សប្បុរសជននៅខេត្តព្រៃវែង	ថវិកាចំនួន	២.១០០ ដុល្លារ
១០- លោកស្រី ឃួន	ចាន់សារី	សប្បុរសជននៅខេត្តកណ្តាល	ថវិកាចំនួន	២.០១០ ដុល្លារ
១១- លោក សែម	ភាព	សប្បុរសជននៅខេត្តកំពង់ស្ពឺ	ថវិកាចំនួន	១.៩០០ ដុល្លារ

មាត្រា ២ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥១០.អនក្រ.កត

អនុក្រឹត្យ
ស្តីពីការជូនគ្រឿងឥស្សរិយយសសហមេត្រីសាកលណ្ណ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសហមេត្រីសាកលណ្ណ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ០៣ រូប ដែលបានលះបង់កំលាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងសមិទ្ធផលផ្សេងៗជាច្រើន នៅ**វត្តពោធិទង** និង **វត្តបាក់តាង** ស្ថិតក្នុងឃុំកញ្ជ្រៀច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

ក- គ្រឿងឥស្សរិយយសសហមេត្រីសាកលណ្ណថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ផ្តល់ជូន

លោក **សួស ធ្រាផ្លា** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ

ខ- គ្រឿងឥស្សរិយយសសហមេត្រីសាកលណ្ណថ្នាក់អស្សរឫទ្ធិចំនួន ០២ គ្រឿង ប្រគេន និងផ្តល់ជូន :

១-ព្រះតេជគុណ **អ៊ុច ស៊ុនណាត** ព្រះចៅអធិការវត្តពោធិទង បច្ច័យចំនួន ១២.៥៥០ ដុល្លារ

២-ឯកឧត្តម **គុយ ម៉ុនសន** ប្រធាននាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ថវិកាចំនួន ១១.៥០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ១៧ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥១១..អនក្រ.កត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនលោក **ស្រ៊ី ថា** ប្រធានផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានភូមិ ឃុំ និងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតក្នុងឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

មាត្រា ២.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តស្វាយរៀង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានលះបង់កំលាំងកាយចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង និង អភិវឌ្ឍន៍មូលដ្ឋានភូមិឃុំ និងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតក្នុងឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានរាយនាមដូចខាងក្រោម :

ក. គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០៣ គ្រឿង ផ្តល់ជូន :

១-លោក **ម៉ុល ខេមរា** អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថវិកាចំនួន ៦៥.០០០ ដុល្លារ

២-លោក **សុខ ខេមរិន** អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថវិកាចំនួន ៦៥.០០០ ដុល្លារ

៣-លោក **ឈាង មុន្នី** អនុប្រធានការិយាល័យ នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថវិកាចំនួន ៦០.០០០ ដុល្លារ

ខ. គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌថ្នាក់អស្សរិទ្ធិចំនួន ០១ គ្រឿង ផ្តល់ជូន

លោក **ឌឹង ស៊ាង** ប្រធានផ្នែក នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថវិកាចំនួន ៤០.០០០ ដុល្លារ

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តស្វាយរៀង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៥៦៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានចំណាយធនធានផ្ទាល់ខ្លួន ក្នុងការជួយកសាងអគារសាលាពុទ្ធិក បឋមសិក្សា ០១ខ្នង មានទទឹង ៨.២០ម៉ែត្រ បណ្តោយ ២៤ម៉ែត្រ និងជីកស្រះទឹកមួយកន្លែង នៅមុខព្រះវិហារ មានទទឹង ៣០ម៉ែត្រ និងបណ្តោយ ៨០ម៉ែត្រ ស្ថិតក្នុងវត្តបទុមវង្សាឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ចំណាយអស់ ថវិកាសរុប ចំនួន ៣៥.៥៧៨ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ធ្លាក់ ផល្លី** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាប្រធានគណៈពង្រឹងមូលដ្ឋានឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល

២-ឯកឧត្តម **ឌី ពុធថាវ៉ា** អនុប្រធានគណៈពង្រឹងមូលដ្ឋានឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៩. សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសេនាសនៈ វត្ត ព្រៃអង្គរក្នុង ស្ថិតក្នុងឃុំជួនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម

- យោងតាមសំណូមពរ និងការងារចាំបាច់

សម្រេច

ប្រការ១.- ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ សេនាសនៈ និងសមិទ្ធិផលនានា វត្តព្រៃអង្គរក្នុង ស្ថិតក្នុងឃុំជួនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ដែលមានសមាភាពដូចខាងក្រោម ÷

១- ឯកឧត្តម	ហ៊ុន ណេង	ប្រធាន
២- ឯកឧត្តម	ខៀវ កាញារីទ្ធ	អនុប្រធាន
៣- ឯកឧត្តម	ថោង ខុន	អនុប្រធាន
៤- ឯកឧត្តម	ស៊ុម ចណ្ណា	សមាជិក
៥- ឯកឧត្តម	ឃឹម សារិទ្ធ	សមាជិក
៦- ឯកឧត្តម	ជា សុខុម	សមាជិក
៧- ឯកឧត្តម	ឡៅ សុចណ្ណថា	សមាជិក

ប្រការ២.- គណៈកម្មការនេះ មានភារកិច្ចរៀបចំកម្មវិធី និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័នមួយចំនួនដែលកាន់ទិសសីមា ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ រួមទាំងសមិទ្ធិផលនានា និងការប្រណាំងទូកង ក្នុងវត្តព្រៃអង្គរក្នុង ស្ថិតក្នុងឃុំជួនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ ហើយអាចបង្កើតអនុគណៈកម្មការជំនាញជាជំនួយការតាមការចាំបាច់ ។

ប្រការ៣.- សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងថ្វាយ-ជូន :

-សម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស

-គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងការពារជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងធម្មការ និងសាសនា

-គណៈកម្មការជាតិរៀបចំបុណ្យជាតិ-អន្តជាតិ

-សាលាខេត្តកំពង់ចាម

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.៧.០៩...២១៣...ប្រ.ក

លិខិតចូល
ថ្ងៃទី១៣...ខែ...ឆ្នាំ200៩

ប្រកាស

ស្តីពី

ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ ៩-៩៥-៤៧ ប្រក ចុះថ្ងៃទី១៦ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

សំរេច

ប្រការ ១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និមួយៗ។

ប្រការ ២.–

រាល់ដំណាច់ខែនីមួយៗ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីអត្រាការប្រាក់ជាមធ្យមដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា ។

ប្រការ ៣.–

ប្រកាសលេខធ ៥-៩៥-៤៧ ប្រក ចុះថ្ងៃទី១៦ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤.–

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥.–

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៥

ទេសាភិបាល

ជា_ចាន់តូ

<u>កន្លែងទទួល</u>

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Unofficial Translation

Number B 7.09-213 Pror Kor

PRAKAS
on
The Liberalization of Interest Rate Setting

****

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 dated December 29, 2006, promulgating the Law on amanment Article 14 and 57 of the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 dated November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 dated May 13, 2008, on the appointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to Prakas B 5-95-47 Pror Kor dated March 16, 1995, on the Liberalization of Interest Rate Setting;
- Pursuant to the request of General Directorate of the National Bank of Cambodia.

DECIDES

Article 1:

Banks and Financial Institutions have the right to determine interest rates on deposits and interest rates on loans both in the local currency and in foreign currencies according to each institution's ability and interest rate policy.

Article 2:

At the end of each month, banks and financial institutions must report in writing to the National Bank of Cambodia on the average interest rates as applied to deposits and loans.

Article 3:

Prakas No B 5-95-47 Pror Kor dated 16 March 1995 on the Liberalization of Interest Rates Setting is hereby null and void.

Article 4:

The Directorate General, the Secretariat General, the Inspection General, the Cashier General, all Departments of the National Bank of Cambodia, and all Bank and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

Article 5:

This Prakas is effective from the signing date.

Phnom Penh, 09 September 2009
Governor
Seal and Signature: Chea Chanto

cc:
-The parties concerned as stated in Article 4
-Administrative
-File
-The member of the Board of Directors
-CM "for info"
- Department of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០៩-២១៦ ប្រក

លិខិតចូល
ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៩

ប្រកាស
ស្តីពី
ការផ្តល់របាយការណ៍ឥណទានធំ
និង
ពិនិត្យតាមដានហានិភ័យឥណទានប្រមូលផ្តុំ

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ៧-០៦-២២៦ ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩

ស ម្រ េ ច

ជំពូក ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា គ្រឹះស្ថាន ត្រូវពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ ប្រចាំត្រីមាស នូវឥណទានធំបំផុតចំនួន ៥០។ គ្រឹះស្ថាន ត្រូវសម្រប និងលើកកំពស់គុណភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ខ្លួន ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

ប្រការ ២.-

ហានិភ័យឥណទានប្រមូលផ្តុំអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ដូច្នេះ តម្រូវឱ្យមានការពិនិត្យតាមដានជាពិសេស ដើម្បីវាយតម្លៃផលប៉ះពាល់ជាសក្តានុពលនៃការធ្លាក់ចុះស្ថានភាពអ្នកខ្ចីធំៗ ក្នុងកាលៈទេសៈដែលសេដ្ឋកិច្ចមិនអំណោយផល។

លើសពីនេះ ទោះបីមានបទប្បញ្ញត្តិទាក់ទងនឹងហានិភ័យឥណទានធំក្តី ក៏ហានិភ័យឥណទានប្រមូលផ្តុំ ត្រូវតែសមស្របទៅនឹងហានិភ័យដែលអាចទទួលយកបាន និងភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។ ហានិភ័យឥណទានដែលត្រូវបានចាត់ទុកថាប្រមូលផ្តុំខ្លាំងពេក តម្រូវឱ្យមានការវាយតម្លៃឡើងវិញនូវគោលនយោបាយ និងកម្រិតកំណត់ឥណទានជាបន្តបន្ទាប់ និងប្រចាំគ្រា។

ប្រការ ៣.-

រាល់ត្រីមាស គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិនូវបញ្ជីអ្នកខ្ចីធំបំផុត ជាឯកត្តជន ឬជាក្រុម ចំនួនហាសិប (៥០)។ របាយការណ៍នេះ ត្រូវមានជាអប្បបរមានូវទិន្នន័យនិងព័ត៌មានទាំងអស់ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

គ្រឹះស្ថាន ត្រូវផ្តល់ឱ្យសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ នូវការវាយតម្លៃសង្ខេបអំពីស្ថានភាពហិរញ្ញវត្ថុជារួមរបស់អ្នកខ្ចី ជាពិសេស បើឥណទានត្រូវបានធ្វើចំណាត់ថ្នាក់មិនល្អ រាល់ឯកសារ ភស្តុតាងដែលមានទិន្នន័យ និងព័ត៌មានគ្រប់គ្រាន់ ត្រូវបានប្រគល់ជូនសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកគណៈប្រតិបត្តិ ដើម្បីវាយតម្លៃអំពីសក្តានុពលនៃការខាតបង់ និងផលប៉ះពាល់ផ្សេងទៀត ជាពិសេស អំពីស្ថានភាពសាច់ប្រាក់ងាយស្រួល និងសាធនភាពរបស់គ្រឹះស្ថាន។

របាយការណ៍ប្រចាំត្រីមាសទាំងនេះ ត្រូវមានបញ្ជាក់អំពីវិធានការណ៍ទាំងអស់ដែលគ្រឹះស្ថានបាននិងត្រូវអនុវត្ត ដើម្បីការពារផលប្រយោជន៍របស់គ្រឹះស្ថាន។

ជំពូក ២

ការរួមបញ្ចូលគ្នានូវហានិភ័យ

ប្រការ ៤.-

នៅពេលដែលឯកត្តជន ឬនីតិបុគ្គលពីរ ឬច្រើនត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ដោយសារតែមានទំនាក់ទំនងទៅវិញទៅមក គ្រឹះស្ថានត្រូវបូកសរុបហានិភ័យទាំងអស់ឱ្យបានត្រឹមត្រូវ និងរាយលំអិតអ្នកខ្ចីនីមួយៗ និងកម្រិតអនុម័តឥណទានដែលបង្កើតបានជាហានិភ័យរួមបញ្ចូលគ្នា។

ប្រការ ៥.-

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែមួយ គឺក្រុមបុគ្គលដែលមានចំណងទាក់ទងទៅវិញទៅមក ដែលប្រសិនបើបុគ្គលមួយឬច្រើនជួបបញ្ហាហិរញ្ញវត្ថុនោះ នឹងនាំឱ្យបុគ្គលផ្សេងទៀតត្រូវតែមានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរផងដែរ ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងបុគ្គលពីរ ឬច្រើននៅពេលណាដែល ៖

ក- បុគ្គលណាមួយគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើបុគ្គលផ្សេងទៀត

ខ- បុគ្គលទាំងឡាយណាដែលជាបុត្តសម្ព័ន្ធរបស់ក្រុមហ៊ុនមេតែមួយ

គ- បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមព្រឹត្តន័យ (de facto management)

ឃ- បុគ្គលណាមួយមានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀតលើសពីដប់ភាគរយ(១០%) ហើយពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាបដិការឬមានទំនាក់ទំនងអាជីវកម្មពិសេសជាមួយគ្នាដូចជា កិច្ចសន្យាបន្តសិទ្ធិប្រើយីហោ (franchise) ។ល។

ធនាគារជាតិនៃកម្ពុជា អាចចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែមួយបើចំណងទាក់ទងរបស់ពួកគេមានដូចខាងលើ ។

ប្រការ ៦.-

លើសពីនេះ គ្រឹះស្ថានអាចកំណត់នូវកត្តាពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ឬទំនាក់ទំនងទៅវិញទៅមកផ្សេងទៀតជាពិសេស ដោយផ្អែកលើការវិភាគប្រភពដើម និងការប្រមូលផ្តុំនៃលំហូរសាច់ប្រាក់ ។

ប្រការ ៧.-

គ្រឹះស្ថាន ត្រូវរួមបញ្ចូលគ្នានូវហានិភ័យទាំងអស់ ឱ្យបានសមស្រប ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពហានិភ័យទាំងមូល ទៅលើសំណុំកូនបំណុលដែលមានទំនាក់ទំនងជាមួយគ្នាជាអ្នកខ្ចីតែមួយ ។

ជំពូក ៣

ទម្រង់ និងខ្លឹមសារ នៃរបាយការណ៍

ប្រការ ៨.-

គ្រឹះស្ថានត្រូវរាយការណ៍តាមគំរូរបាយការណ៍ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។ របាយការណ៍នេះ ត្រូវតែមានខ្លឹមសារគ្រប់គ្រាន់អាចទទួលយកបាន។ ហានិភ័យឥណទានធំបំផុតចំនួន ៥០ ត្រូវតែបានបង្ហាញតាមលំដាប់ចំនួនប្រាក់ថយចុះ ។

ប្រការ ៩.-

រូបវ័ន្តបុគ្គល និងនីតិបុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកជាអ្នកខ្ចីតែមួយ ត្រូវតែសម្គាល់អត្តសញ្ញាណឱ្យបានច្បាស់លាស់ និងត្រូវតែបញ្ជាក់អំពីប្រភេទនៃទំនាក់ទំនងទៅវិញទៅមក។ ព័ត៌មានលំអិតអំពីទំនាក់ទំនងក្នុងចំណោមសមាសភាពទាំងឡាយនៃក្រុមអ្នកខ្ចី ត្រូវមានឧបសម្ព័ន្ធភ្ជាប់មកជាមួយរបាយការណ៍។

ព័ត៌មានអំពីអត្តសញ្ញាណទាំងនោះត្រូវមានជាអប្បបរមា ដូចខាងក្រោម ÷

- រូបវ័ន្តបុគ្គលៈ នាមនិងគោត្តនាមទាំងអស់ដែលប្រើជាផ្លូវការ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន មុខរបរ/វិជ្ជាជីវៈ និង វិស័យសេដ្ឋកិច្ច
- នីតិបុគ្គលៈ នាមករណ៍ ឃីហោ លេខចុះបញ្ជីពាណិជ្ជកម្ម ថ្ងៃបង្កើតក្រុមហ៊ុន អាសយដ្ឋានក្រុមហ៊ុន មុខរបរ វិស័យសេដ្ឋកិច្ច និងព័ត៌មានផ្សេងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃអត្តសញ្ញាណ។

មុនពេលរួមបញ្ចូលហានិភ័យរបស់នីតិបុគ្គល និង/ឬរូបវ័ន្តបុគ្គលដែលត្រូវបានចាត់ថាជាអ្នកខ្ចីតែមួយ គ្រឹះស្ថានត្រូវរាយលំអិតបុគ្គលនីមួយៗតាមកម្រិតអនុម័តឥណទានទាំងអស់។

ការរួមបញ្ចូលគ្នាត្រូវអនុវត្តដោយបូកសរុបដោយឡែកពីគ្នារវាងសមតុល្យដក់សល់ដុលក្នុងតារាងតុល្យការ និងសមតុល្យជាប់កិច្ចសន្យានៃខ្ទង់ក្រៅតារាងតុល្យការ។

ប្រការ ១០.-

ចំនួនហានិភ័យឥណទានក្នុងតារាងតុល្យការត្រូវតែរាយការណ៍ដោយប្រើចំនួនដុល ដែលជាចំនួនប្រាក់ដើមដក់សល់ ដោយមិនបញ្ចូលសំវិធានធនជាក់លាក់ និងការប្រាក់ លើកលែងតែការប្រាក់នោះត្រូវបានបូកបញ្ចូលជាប្រាក់ដើមដូចមានចែងក្នុងកិច្ចសន្យា។

ហានិភ័យឥណទានធំត្រូវបានរាយលំអិតតាមកម្រិតអនុម័តឥណទាននិងតាមអ្នកខ្ចីនីមួយៗ។ ព័ត៌មានអប្បបរមាដែលត្រូវមាន គឺប្រភេទហានិភ័យ (ឥណទានវិបារូបន៍ ឬឥណទាន) ប្រាក់ដើមដក់សល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង ប្រភេទនៃការរំលោះ និងកាលវសាន្ត។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្ទង់ដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ។

ប្រការ ១១.-

ហានិភ័យក្រៅតារាងតុល្យការត្រូវតែបានរាយការណ៍ ដោយបូកបញ្ចូលនូវចំនួនសមតុល្យជាប់កិច្ចសន្យា ដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍ ។

កម្រិតអនុម័តឥណទាននោះ ត្រូវតែបានរាយលំអិតតាមអត្ថគាហកនីមួយៗ ហើយឆ្លុះបញ្ចាំងពីចំនួនសមតុល្យជាប់កិច្ចសន្យាដែលនៅសល់ ចំនួនប្រាក់ដែលបានអនុម័តដំបូង និងពីកាលវសាន្តបើមាន ហើយត្រូវតែមានបញ្ជាក់ច្បាស់អំពីប្រភេទប្រតិបត្តិការ (ឥណទានវិបារូបន៍ដែលមិនបានប្រើ ការសន្យាឥណទានដែលមិនទាន់បានប្រើប្រាស់ ការធានានិងប្រភេទនៃការធានា) ។

បើកម្រិតអនុម័តឥណទានឬអ្នកខ្ចីត្រូវបានចាត់ថ្នាក់មិនល្អ នៅក្នុងកិច្ចបញ្ជិកាគណនី និងកំណត់ត្រារបស់គ្រឹះស្ថាន របាយការណ៍ត្រូវឆ្លុះបញ្ចាំងក្នុងខ្លួនដោយឡែកពីគ្នានូវការចាត់ថ្នាក់ដែលសមស្រប និងការបង្កើតសំវិធានធនជាក់លាក់លើហានិភ័យនោះ ។

ជំពូក ៤

កាលបរិច្ឆេទនៃរបាយការណ៍

ប្រការ ១២.-

គ្រឹះស្ថានទាំងអស់ ត្រូវធ្វើរបាយការណ៍អំពីហានិភ័យឥណទានធំបំផុតចំនួន ៥០ ប្រចាំត្រីមាសគិតត្រឹមចុងខែមិនា មិថុនា កញ្ញា និងធ្នូ មកធនាគារជាតិនៃកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ ខែទីមួយនៃត្រីមាសបន្ទាប់ ។

ជំពូក ៥

ទណ្ឌកម្ម

ប្រការ ១៣.-

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ជំពូក ៦

អវសានប្បញ្ញត្តិ

ប្រការ ១៤.-

ប្រកាសនេះមិនអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឡើយ ។

ប្រការ ១៥.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ១៦.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។/៕

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០០៩

ទេសាភិបាល

ជា-ចាន់តូ

កន្លែងទទួល

- ដូចប្រការ ១៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

ចម្លងជូន

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ឧបសម្ព័ន្ធ

QUATERLY BIGGEST EXPOSURES REPORT

As of ....

ឈ្មោះធនាគារ/Bank's Name:

In USD

Exchange Rate. ....

No.	Borrowers' Names/Exposures' Consolidation (Art. 7)		Types/Reasons of connection (Art. 5 or 6)	Borrowers' Address	Borrowers' National ID / Date of Birth / Business License N°	Business Activity / Profession	Contractual Maturity*		Type of Amortization	Nature of Exposure *	Initial Approved Limited		Approved Limited		Type of Classification *	Total Outstanding On-Balance Sheet (Gross Basis)		Amount of Specific Provision (On BS)		Total Outstanding Off-Balance Sheet (Notional Amount Basis)		Amount of Specific Provision (Off BS)		Comments
	Exposures' consolidation	Individuals/legal entities					From	To			KHR*	USD	KHR*	USD		KHR*	USD	KHR*	USD	KHR*	USD	KHR*	USD	
សរុប/Total																								

* Note:

[illegible]

1. Biggest Exposures shall be presented in decreasing order of amounts

[illegible]

2. If there is no contractual maturity, please allocate the notes in this report for the reasons.

[illegible]

3. Nature of exposures shall be noted the full name of each type i.e. OD for Overdraft and this column applies to both on- and off- balance sheet items.

[illegible]

4. If ... is extended in KHR, it should be shown in KHR column and converted to USD according to NBC's exchange rate.

[illegible]

5. Type of classification ... both On- and Off- Balance Sheet should be left a Blank Box for assets that are not classified and abbreviated as: SM for Special Mention, SS for Substandard Loan, D for Doubtful Loan, and L for Loss Loan and should be in accordance with Prakas N° B7-09-074 Prakor

Manager

Checked By

Reporting Date.

Prepared By

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.09.216 Prorkor

Unofficial Translation

Prakas

on

Reporting of the Biggest Exposures and Surveillance of Credit Risk Concentration

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036, dated December 29, 2006, promulgating the Law on the amendment articles 14 and 57 of the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008, on the reappointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Prakas B7-06-226 on the Controlling Banks and Financial Institutions' Large Exposures;
- Pursuant to the recommendation made by National Bank of Cambodia management during the September 03, 2009, meeting.

DECIDES

Chapter 1

General Provisions

Article 1

Banking and Financial institutions, hereafter called "Institutions," are required to establish, on a quarterly basis, a comprehensive review of their fifty biggest exposures on borrowing counterparties. Where required, institutions shall adapt and upgrade their

management information systems in order to comply with the requirements set forth in this Prakas.

Article 2

Credit risk concentration issues might severely impact an institution's financial condition, therefore requiring particular surveillance in order to assess potential impacts of a deteriorating larger borrower's condition under adverse economic circumstances.

In addition, notwithstanding the regulatory requirements related to large exposures, the concentration of credit exposures shall be commensurate with the institution's risk appetite and the strength of financial condition. Credit exposures deemed too concentrated shall lead to a reassessment of lending policies and limits, subsequently and on a periodic basis.

Article 3

On a quarterly basis, Institutions shall provide Board Members or Members of the Executive Body with a list of the fifty (50) largest exposures on individual borrowers or groups of borrowers. Such reports shall, at a minimum, include all the data and information required by the banking supervisory authority, the National Bank of Cambodia.

Institutions shall provide Board Members or Members of the Executive Body with a summary assessment on the borrowers' overall financial condition. In particular, should the reported exposures be adversely classified, all adequate supporting data and information should be communicated in order to evaluate potential losses and other impacts, especially on the institution's liquidity and solvency condition.

These quarterly reports to the Board Members or to the Members of the Executive Body shall inform them of all the actions undertaken so far by the institution and the actions currently considered to safeguard its interests.

Chapter 2

Exposures' consolidation

Article 4

When two or several individuals or legal entities are considered a single borrower due to their interconnections, institutions shall aggregate the overall exposures at the adequate level and itemize all the individual borrowers and lines constituting the consolidated exposures.

Article 5

Individuals or legal entities that are interconnected in such a way that financial problems experienced by one or more of them would necessarily entail serious financial problems for the other or all of them shall likewise be deemed to constitute a single beneficiary.

In particular, such connections exist between two or more individuals or legal entities where:

a) One of them directly or indirectly exercises control over the other(s);
b) They are subsidiaries of the same parent company;
c) They come under the same *de facto* management;
d) One of them has an equity interest in the other exceeding 10 percent and they are bound by reciprocal guarantee agreements or have a special business relationship with each other such as sub-contracting, franchise, etc.

The National Bank of Cambodia shall regard a group of borrowers as constituting a single beneficiary if the connections between them fall under the aforementioned.

Article 6

In addition, Institutions might identify other economic dependence factors or interconnections, especially based on internal analyzes performed on cash-flow origins and concentrations.

Article 7

Institutions shall consolidate all their exposures at the appropriate level to reflect their overall risk on the ensemble of interconnected debtors, considered a "single borrower."

Chapter 3

Reporting Format and Content

Article 8

Institutions shall report according to the sample as attached in the Appendix. This report shall contain sufficient data. The overall fifty largest exposures shall be presented in decreasing order of amount.

Article 9

Individuals and legal entities, considered "single borrowers," shall be clearly identified and the types of interconnections explicitly discussed. Detailed information about relationships among the different components of such groups of borrowers shall be in an appendix attached with the report.

For identification, the minimum required information shall be as below:

- **For individuals:** full legal name used, birth date, address, activity / profession, economic sector;
- **For legal entities:** commercial name, brands, registration number, incorporation date, business address, activity(ies), economic sector and any other useful information available to ensure proper identification.

Prior to consolidation of the exposures held on individuals and/or legal entities considered as "single borrowers," institutions shall itemize all lines extended at the individual level.

Consolidation shall be performed by **aggregating separately** on-balance sheet items on a gross outstanding basis, and off-balance sheet items on an outstanding notional amount basis.

Article 10

The amount of balance-sheet exposures shall be reported on a gross basis that is outstanding capital, without considering existing specific provisions and without taking into consideration interests, except if these were contractually capitalized.

The exposures shall be itemized, line by line and borrower by borrower. Minimum information required is: nature of exposure (overdraft or loan), outstanding capital, initial authorization, type of amortization and maturity.

Should a line or a borrower be adversely classified in the Institution's books and records, the report shall reflect in separate columns, the corresponding classification and the amount of specific provision established to cover the risk.

Article 11

Off-balance sheet exposures shall be reported and aggregated on an outstanding notional amount basis and as of the reporting date.

The corresponding lines shall be itemized, beneficiary by beneficiary, and reflect the outstanding notional amounts, the initial authorizations and, where applicable, their maturities. The reported lines shall clearly specify the nature of the transactions (unused committed overdraft facility, undisbursed portions of loans, guarantees and types of guarantees).

Should a line or a borrower be adversely classified in the institution's books and records, the report shall reflect, in separate columns, the corresponding classification and the amount of specific provision established to cover the risk.

Chapter 4

Quarterly report to the NBC

Article 12

Institutions shall submit their quarterly reports on their fifty largest exposures, as of the end of March, end of June, end of September and end of December, to the NBC by the 15th of the first month of the following quarter.

Chapter 5

Sanctions

Article 13

Banks and Financial Institutions that are not compliant with this Prakas will be penalized according to Article 52 of the Law on Banking and Financial Institutions.

Chapter 6

Enforcement

Article 14

This Prakas shall not apply to microfinance institutions.

Article 15

The General Directorate, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

Article 16

This Prakas shall have effect from the signing date.

Phnom Penh, 15 September 2009

The Governor

Signed and Sealed : CHEA CHANTO

cc:
- All members of the Board of Directors
- The parties concerned as stated in Article 15
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២០៧ បទ.ប្រក.

.ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

ប្រកាស

ស្តីអំពី

ការតភ្ជាប់បណ្តាញទូរគមនាគមន៍

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០០២ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២៦៧ បទ.ប្រក.

ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

ប្រកាស

ស្តីអំពី

ការតភ្ជាប់បណ្តាញទូរគមនាគមន៍

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០០២ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,

- បានឃើញគោលការណ៍និយ័តកម្មនៃវិស័យទូរគមនាគមន៍របស់អង្គការពាណិជ្ជកម្មពិភពលោក និង សហភាពទូរគមនាគមន៍អន្តរជាតិ,
- យោងប្រកាសលេខ ២៨៩ បទ.ប្រក ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០៣ ស្តីពីការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ,
- យោងសេចក្តីសម្រេចលេខ ១៩៤ បទ.សសរ ចុះថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងាររបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីរៀបចំគោលនយោបាយថ្មីនៃការភ្ជាប់បណ្តាញនិងអាជីវកម្មទូរគមនាគមន៍,
- យោងសាភចអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ១៦៧៧ ស.ហ.វ.- ប.ទ. ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០០៩ ស្តីអំពីវិធានការទប់ស្កាត់ភាពពុំស្មោះត្រង់នៃការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍,
- យោងសេចក្តីត្រូវការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ៗ

សម្រេច

ផ្នែកទី ១

គោលការណ៍សម្រាប់ចរាចរលើសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍

ប្រការ ១ : និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសទាំងឡាយក្នុងប្រកាសនេះមានដូចតទៅៈ

- ការតភ្ជាប់បណ្តាញរវាងគ្នា គឺជាការតភ្ជាប់ដោយរូបវ័ន្ត និង ឡូស៊ីករវាងបណ្តា ទូរគមនាគមន៍ដែលតាមរយៈនោះអ្នកប្រើប្រាស់សេវាអាចទាក់ទងគ្នាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតៗ

- មណ្ឌលនៃការតភ្ជាប់បណ្តាញ គឺជាបណ្តាញមួយដែលកើតឡើងពីការតភ្ជាប់នៃបមាណីទូរស័ព្ទទាំងឡាយទៅនឹងមជ្ឈមណ្ឌលបមាណីកណ្តាលមួយដែលមានសមត្ថភាព និង គុណភាពស្របទៅតាមការកំណត់របស់ក្រសួង

ប្រៃសណីយ៍និងទូរគមនាគមន៍។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជ្រើសរើសយកបណ្តាញនៃការតភ្ជាប់នោះជាសណ្ឋាន « ស្តារ » (Star Topology)។

- **ចំណុចតភ្ជាប់** (Point Of Interconnection " POI ") គឺជាចំណុចស្ថិតនៅលើផ្លូវតភ្ជាប់រវាងបមាណីទូរស័ព្ទពីរ មានចែកព្រំប្រទល់ទទួលខុសត្រូវលើសេដ្ឋកិច្ច បច្ចេកទេសរវាងបណ្តាញទូរគមនាគមន៍ និង ក្រុមហ៊ុនទាំងពីរ ។

- **ទិសដៅតភ្ជាប់** (Direction) គឺជាខ្សែតភ្ជាប់រវាងបមាណីទូរស័ព្ទដែលចូលរួមការតភ្ជាប់ដោយរៀបជាក្រុមផ្លូវសម្រាប់ប្រើប្រាស់តាមកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់រវាងក្រុមហ៊ុនទាំងនោះ។

- **ផ្លូវ** E1 គឺជាផ្លូវ Digital បបមមានល្បឿន 2048 Kb/s តាមនិយមន័យក្នុងឯកសារ ITU-G.701។

- **ផ្លូវ** STM-1 គឺជាផ្លូវ Digital បបមមានល្បឿន 155.52 Mb/s តាមនិយមន័យក្នុងឯកសារ ITU-G.701។

- **ថ្ងៃជួលជារខែ ផ្លូវ** E1 **ក្នុងខេត្ត-ក្រុង** គឺជាថ្លៃជួលជារប្រចាំខែនៃផ្លូវ E1 ក្នុងខេត្ត-ក្រុង ដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដាក់ឱ្យអនុវត្ត។

- **ក្រុមហ៊ុនផ្តល់ការតភ្ជាប់** គឺជាក្រុមហ៊ុនមួយដែលក្រុមហ៊ុនមួយផ្សេងទៀតស្នើសុំតភ្ជាប់ជាមួយ។

- **ក្រុមហ៊ុនសុំការតភ្ជាប់** គឺជាក្រុមហ៊ុនមួយស្នើទៅក្រុមហ៊ុនមួយផ្សេងទៀតសុំផ្តល់ការតភ្ជាប់។

- **ការតភ្ជាប់ផ្ទៃក្នុង** គឺជាការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងអង្គភាពផ្សេងៗក្រោមឱវាទក្រុមហ៊ុនតែមួយ។

- **ការតភ្ជាប់ឆ្លងប្រព័ន្ធ** គឺជាការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងក្រុមហ៊ុនពីរខុសគ្នា។

ប្រការ ២ : គោលបំណង

គោលបំណងនៃប្រកាសនេះ គឺដើម្បី៖

- កំណត់សិទ្ធិនិងកាតព្វកិច្ចនៃប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មាន

អនុញ្ញាតផ្តល់សេវាទូរគមនាគមន៍សម្រាប់ការតភ្ជាប់ទៅវិញទៅមកក្នុងព្រះរាជាណាចក្រកម្ពុជា។

- កំណត់ថេរវេលា ខ្លឹមសារ និងល័ក្ខខ័ណ្ឌសម្រាប់ការតភ្ជាប់ទៅវិញទៅមកនៃប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

- បង្កើតនីតិវិធីសម្រាប់ការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

- បង្កើតនីតិវិធីសម្រាប់ដោះស្រាយវិវាទដែលទាក់ទងនឹងការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

- ជំរុញឱ្យមានការប្រកួតប្រជែងក្នុងទីផ្សារទូរគមនាគមន៍នៅកម្ពុជាប្រកបដោយតម្លាភាព ស្មើភាពនិងស្មោះត្រង់។

- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ថ្មី និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព។

- បង្កើនសេវាទូរគមនាគមន៍ជូនសាធារណជនប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

ប្រការ ៣ : វិសាលភាពអនុវត្ត

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ជូនសាធារណជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤ : សិទ្ធិ និង ភាតព្វកិច្ចក្នុងការតភ្ជាប់

អតិថិជនរបស់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍អាចភ្ជាប់ជាមួយអតិថិជនរបស់ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍មួយផ្សេងទៀត ហើយក៏អាចប្រើប្រាស់សេវាដែលផ្តល់ដោយប្រតិបត្តិករទូរគមនាគមន៍ដទៃទៀតដែរ។

ប្រតិបត្តិករដែលកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតផ្តល់សេវាទូរគមនាគមន៍ត្រូវធានាឱ្យមានការតភ្ជាប់បណ្តាញជាមួយប្រតិបត្តិករទូរគមនាគមន៍ផ្សេងទៀតសម្រាប់អ្នកប្រើប្រាស់សេវាទូរគមនាគមន៍ក្នុងនិងក្រៅប្រទេស។

ការតភ្ជាប់ត្រូវធានានូវរាល់ចំណុចតភ្ជាប់ណាដែលអាចធ្វើទៅបានតាមលក្ខណៈ

បច្ចេកទេសក្នុងបណ្តាញរបស់ប្រតិបត្តិករផ្តល់សេវា។ការតភ្ជាប់នៅចំណុចតភ្ជាប់ផ្សេងទៀតក្នុងបណ្តាញត្រូវផ្តល់តាមការស្នើសុំ ហើយថ្លៃតភ្ជាប់ត្រូវឆ្លុះបញ្ចាំងលើថ្លៃដើមនៃការសាងសង់និងការបំពាក់បន្ថែមនូវសម្ភារៈបរិក្ខារដែលចាំបាច់។

ការតភ្ជាប់ត្រូវផ្តល់ដោយៈ

- ពុំរើសអើងចំពោះថេរវេលា ល័ក្ខខ័ណ្ឌ (បទដ្ឋាននិងលក្ខណៈបច្ចេកទេស) និងអត្រាថ្លៃតភ្ជាប់ ហើយយ៉ាងហោចណាស់ត្រូវមានគុណភាពដូចសេវាដែលតភ្ជាប់ក្នុងបណ្តាញខ្លួន ឬ សេវាស្រដៀងគ្នានឹងសាខារបស់ខ្លួន។
- ទាន់ពេលវេលា។
- មានគោលការណ៍តម្លាភាព ថេរវេលា ល័ក្ខខ័ណ្ឌនិងអត្រាថ្លៃតភ្ជាប់ផ្អែកលើមូលដ្ឋានថ្លៃដើមដែលសមហេតុផល។
- ឈរលើគោលការណ៍គណនាថ្លៃដាច់ដោយឡែកពីគ្នា ដើម្បីចៀសវាងចំណាយលើសេវាមិនចាំបាច់។

ប្រតិបត្តិករផ្តល់ការតភ្ជាប់ត្រូវថែរក្សាការតភ្ជាប់ និង ផ្តល់ការប្រើប្រាស់សេវាពាក់ព័ន្ធផ្សេងៗទៀតស្របតាមពាក្យស្នើសុំតភ្ជាប់។

ប្រការ ៥ : កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់បណ្តាញ

ពាក្យស្នើសុំតភ្ជាប់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីទម្រង់នៃការស្នើសុំតភ្ជាប់ កាលបរិច្ឆេទ និង ការប៉ាន់ស្មានចំណុះល្បឿននៃការតភ្ជាប់ដែលត្រូវការ។

ក្រុមហ៊ុនដែលកាន់អាជ្ញាប័ណ្ណផ្តល់សេវាទូរគមនាគមន៍ត្រូវចេញផ្សាយកិច្ច-ព្រមព្រៀងស្តីពីការតភ្ជាប់ជាសាធារណៈ។

ការចរចាពាណិជ្ជកម្មជាមធ្យោបាយសំខាន់ក្នុងការឈានដល់ចុះកិច្ចព្រមព្រៀងដែលទាក់ទងនឹងការតភ្ជាប់។ ភាគីទាំងអស់ត្រូវចរចាគ្នាដោយសុទ្ធចិត្ត និង ផ្អែកលើមូលដ្ឋានតាមពេលវេលាកំណត់ណាមួយ។

ការចរចាលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់គ្នាពុំត្រូវហួសពី ៣ ខែបន្ទាប់ពីបានដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករ (ក្រុមហ៊ុន) ផ្តល់ការតភ្ជាប់។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិពុំយល់ព្រមពន្យារពេល ប្រសិនបើគ្មានពាក្យស្នើសុំពីភាគីចរចាក្នុងករណីជាក់លាក់ណាមួយនោះ។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់និងក្រុមហ៊ុនដែលស្វែងរកការតភ្ជាប់ត្រូវផ្តល់ព័ត៌មានអំពីវិក្កយបត្រទូទាត់ការប្រើប្រាស់សេវាដែលពាក់ព័ន្ធទៅវិញទៅមកឱ្យបានទៀងទាត់។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវចែងអំពីខ្លឹមសារ និង ល័ក្ខខ័ណ្ឌរវាងភាគីដែលទាក់ទងនឹងការតភ្ជាប់។ ខ្លឹមសារនៃកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ត្រូវមាន៖

- វិសាលភាព និង ភាពជាក់លាក់នៃការតភ្ជាប់របស់ប្រភេទសេវាកម្ម,
- លទ្ធភាពអាចប្រើប្រាស់សេវាកម្មផ្សេងៗ និង ទីកន្លែងទាំងអស់ ដែលចាំបាច់សម្រាប់ផ្តល់ការតភ្ជាប់,
- កម្រិតសេវាកម្ម និង ការថែរក្សាគុណភាពសេវាកម្មពីចុងម្ខាងទៅចុងម្ខាងទៀត,
- ការបង់ថ្លៃតភ្ជាប់ និង ថ្លៃប្រើប្រាស់,
- វិធីគិតវិក្កយបត្រ និង ការទូទាត់,
- របៀបរៀបរយ ការព្យាករ ការផ្តល់ព័ត៌មាន និង នីតិវិធីនៃការសាកល្បង,
- ការផ្តល់ចំណុះ ល្បឿនតភ្ជាប់នៅរាល់ចំណុចតភ្ជាប់ណាដែលបច្ចេកទេសអាចធ្វើទៅបាន,
- ការបញ្ជូនទិន្នន័យស៊ីញ៉ាល់ចាំបាច់ ដែលទាក់ទងទៅនឹងសេវាកម្ម,
- ការផ្តល់ព័ត៌មានទាក់ទងនឹងទំនើបកម្ម ឬ សនិទានកម្មប្រព័ន្ធ,
- លក្ខណៈពិសេសផ្នែកបច្ចេកទេស បទដ្ឋាន និង ការសាកល្បងអន្តរប្រតិបត្តិការ,
- ការគ្រប់គ្រងប្រព័ន្ធ ចរាចរសន្ទនា ថែទាំ និង វាស់ស្ទង់,
- ការរក្សាការសម្ងាត់នៃព័ត៌មាន,
- រយៈពេល វិធីចរចា និង ការពិនិត្យឡើងវិញ,
- វិធីដោះស្រាយវិវាទ។

គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវរៀបចំកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ រួចដាក់ជូនបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ពិនិត្យសម្រេច។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវពិនិត្យសម្រេចលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែលប្រតិបត្តិករទូរគមនាគមន៍ដាក់ជូន។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចអនុម័តយល់ព្រម បដិសេធ ឬ កែប្រែកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែល រៀបចំឡើងដោយក្រុមហ៊ុន។ បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរក្សាបញ្ជីឈ្មោះនៃកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ដែលបានអនុម័តរួចហើយ។

មានតែបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទេ ទើបមានសិទ្ធិអនុម័តការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

ប្រការ ៦ : មូលដ្ឋានកំណត់ថ្លៃតភ្ជាប់

អត្រាថ្លៃដើមត្រូវកំណត់យកជាមូលដ្ឋានសម្រាប់គិតថ្លៃតភ្ជាប់ដែលបោះពុម្ពផ្សាយដោយបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ថ្លៃតភ្ជាប់ត្រូវមានតម្លាភាព និង ត្រូវបែងចែកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាថា មានតែថ្លៃដើមសេវាកម្មដែលប្រើក្នុងការតភ្ជាប់ទេ ដែលត្រូវបញ្ចូលក្នុងការគិតថ្លៃ។

ភាគីនីមួយៗដែលពាក់ព័ន្ធនឹងសេវាតភ្ជាប់ ត្រូវទទួលខុសត្រូវចំពោះការចំណាយលើទីកន្លែងតភ្ជាប់ប្រព័ន្ធ គ្រប់គ្រងបណ្តាញនិងបមាណីទូរស័ព្ទ ដើម្បីទ្រទ្រង់ចំណុចតភ្ជាប់ (Point Of Interconnection " POI ") ហើយភាគីទាំងអស់ត្រូវចែកគ្នាចេញថ្លៃលើសមត្ថភាពរបស់បណ្តាញតភ្ជាប់។

ប្រការ ៧ : លក្ខខណ្ឌបច្ចេកទេស

ក្រុមហ៊ុនស្វែងរកការតភ្ជាប់ ត្រូវផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់ទាក់ទងនឹងចំណុចតភ្ជាប់ ដើម្បីឱ្យក្រុមហ៊ុនដែលផ្តល់ការតភ្ជាប់កំណត់លក្ខណៈបច្ចេកទេសចាំបាច់សម្រាប់ធ្វើការវិភាគថ្លៃដើមនៃការបង្កើតចំណុចតភ្ជាប់។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់ត្រូវបង្កើតចំណុចតភ្ជាប់ឱ្យបានឆាប់ បន្ទាប់ពីមានការសម្រេចលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ដោយពុំត្រូវលើស ៣០ ថ្ងៃឡើយ។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ត្រូវកំណត់គុណភាពសេវាឱ្យស្របតាមការអនុវត្តតភ្ជាប់ជាក់ស្តែងដែលល្អ ហើយត្រូវផ្តល់មូលហេតុចំពោះការមិនបានបំពេញតាមកម្រិតគុណភាពសេវាទាំងនោះ។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវកំណត់គុណភាពសេវា ប្រសិនបើភាគីទាំងអស់មិនបានគោរពតាមកិច្ចព្រមព្រៀង។

ទិន្នន័យនៃការបញ្ជូនស៊ីញ៉ាល់ (Signaling Data) ចាំបាច់ត្រូវបញ្ជូនរវាងភាគីតភ្ជាប់ឱ្យស្របតាមបទដ្ឋានអន្តរជាតិនិងល័ក្ខខ័ណ្ឌតម្រូវទាំងអស់ ដែលចេញដោយបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រុមហ៊ុនដែលមានបំណងផ្លាស់ប្តូរផែនការពាក់ព័ន្ធនឹងប្រព័ន្ធទូរគមនាគមន៍ត្រូវផ្តល់ព័ត៌មានយ៉ាងតិច ៦ ខែមុន ជូនភាគីតភ្ជាប់ដទៃ ដើម្បីកុំឱ្យប៉ះពាល់សេវាទូរគមនាគមន៍របស់ភាគីតភ្ជាប់។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវទទួលបន្ទុកចេញវិក្កយបត្រទូទាត់ថ្លៃសេវាដែលបានប្រើប្រាស់ជូនអតិថិជនរបស់ខ្លួន។

ប្រការ ៨ : ការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់

ការផ្អាក ឬ បញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ពុំអាចធ្វើទៅបានទេ ប្រសិនបើគ្មានការយល់ព្រមពីបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនា-គមន៍ជាមុន។

ក្រុមហ៊ុនផ្តល់ការតភ្ជាប់អាចបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ តែក្នុងករណីមានការរំលោភលើកិច្ចព្រមព្រៀង និង ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនផ្តល់ការតភ្ជាប់ បានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនអំពីគោលបំណងចង់បញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់,
- ក្រុមហ៊ុនស្វែងរកការតភ្ជាប់បានផ្តល់ឱកាស ដើម្បីដោះស្រាយបញ្ហាក្នុងការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់,
- ក្រុមហ៊ុនផ្តល់ការតភ្ជាប់បានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពីបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យបញ្ចប់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ ពុំត្រូវអនុញ្ញាតឱ្យមានការផ្អាក ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមកទេ លើកលែងតែក្នុងករណីចាំបាច់ដែលត្រូវបញ្ជាក់អំពីការកាត់បន្ថយសម្ភារៈនៃប្រព័ន្ធសេវាទូរគមនាគមន៍ ឬ ក្នុងករណីមានការគំរាមកំហែងចំពោះសម្ភារៈថែរក្សាការតភ្ជាប់។

ប្រការ ៩ : ការដោះស្រាយវិវាទ

១) កម្មវត្ថុវិវាទនៃសមត្ថភាពតភ្ជាប់បណ្តាញ

ក) ផែនការសមត្ថភាពតភ្ជាប់,

ខ) ការចុះកិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់,

គ) ការកែប្រែផ្លាស់ប្តូរផែនការសមត្ថភាពតភ្ជាប់,

ឃ) ការពង្រីកសមត្ថភាពតភ្ជាប់,

ង) បញ្ហាផ្សេងៗនៅពេលអនុវត្តកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

២) នីតិវិធីនៃការដោះស្រាយវិវាទ

ក) ឯកសារស្នើសុំដោះស្រាយវិវាទ ដែលត្រូវផ្ញើមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍រួមមាន៖

- ឯកសារស្នើសុំដោះស្រាយវិវាទ,
- ឯកសារសេដ្ឋកិច្ច បច្ចេកទេស និង ភស្តុតាងដែលពាក់ព័ន្ធ,
- សំណូមពរ (បើមាន)។

ខ) អាសយដ្ឋានទទួលឯកសារដោះស្រាយវិវាទ :

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កាច់ជ្រុងផ្លូវលេខ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

 អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ :

 ◎ ទូរស័ព្ទលេខ ០១២ ៧០ ៧១ ៧២, ០១៦ ៧០ ៧១ ៧២

 ◎ ទូរសារលេខ ០២៣ ៧២ ២៩ ៨១

 ◎ E-mail : soksamnang78@hotmail.com។

គ) នីតិវិធីដោះស្រាយវិវាទ

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សម្រេចទទួលដោះស្រាយ ឬ ពុំដោះស្រាយវិវាទក្នុង រយៈពេល ១៤ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលឯកសារតវ៉ាដែលស្របច្បាប់។
- ក្នុងករណីកម្មវត្ថុដែលលើកឡើងនៅក្នុងឯកសារមិនស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវធ្វើលិខិតឆ្លើយតបជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់-លាស់អំពីមូលហេតុនិងធ្វើការណែនាំ ប្រសិនបើមាន។
- ក្នុងករណីសម្រេចទទួលដោះស្រាយវិវាទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវដោះស្រាយជាជំហានៗដូចតទៅៈ

ជំហានទី ១

ពិនិត្យមើលភាពស្របច្បាប់នៃខ្លឹមសារទាំងឡាយក្នុងសំណុំឯកសារ។ ក្នុងករណីចាំបាច់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបង្កើតក្រុមបេសកកម្មចុះពិនិត្យលើកម្មវត្ថុវិវាទនិងវាស់វែងតាមជាក់ស្តែង ដើម្បីវាយតម្លៃ រួចកំណត់មូលហេតុសំដៅទៅដោះស្រាយវិវាទលើការតភ្ជាប់។

ក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការតភ្ជាប់ត្រូវផ្តល់ទិន្នន័យគ្រប់គ្រាន់និងទាន់ពេលវេលា ផ្តល់ឧបករណ៍ ព្រមទាំងចាត់អ្នកឯកទេសឱ្យចូលរួមជាមួយក្រុមត្រួតពិនិត្យប្រសិនបើមានការស្នើសុំ។

ជំហានទី ២

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវធ្វើការសម្របសម្រួលការចរចាជាមួយភាគីពាក់ព័ន្ធ។

ជំហានទី ៣

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ចេញសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចដោះស្រាយវិវាទ។

ជំហានទី ៤

ក្រុមហ៊ុនត្រូវអនុវត្តតាមខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចដោះស្រាយវិវាទ។

ឃ) ក្នុងករណីក្រុមហ៊ុនពុំឯកភាពចំពោះខ្លឹមសារក្នុងសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទេ ក្រុមហ៊ុននោះអាចធ្វើពាក្យស្នើសុំដោះស្រាយវិវាទបន្តទៅរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីពិនិត្យ ដោះស្រាយឡើងវិញ។ នៅចន្លោះពេលធ្វើពាក្យស្នើសុំដោះស្រាយវិវាទបន្តទៅទៀត និង រង់ចាំលទ្ធផលដោះស្រាយថ្មី ភាគីទាំងនោះត្រូវអនុវត្តតាមសេចក្តីជូនដំណឹង ឬ សេចក្តីសម្រេចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បណ្តោះអាសន្នសិន។

ភាគីណាមួយដែលធ្វើការចរចាលើកិច្ចព្រមព្រៀងអាចស្នើបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យធ្វើការស៊ើបអង្កេត និង ធ្វើការសម្រេច ដើម្បីដោះស្រាយវិវាទ។ ពាក្យស្នើសុំដាក់ជូនបញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវទទួលយកពាក្យស្នើសុំអន្តរាគមន៍ដោយផ្អែកលើមូលដ្ឋានព័ត៌មានដើម្បីដោះស្រាយវិវាទ ព្រោះថាវិវាទនឹងពុំអាចដោះស្រាយបានទេ ប្រសិនបើគ្មានអន្តរាគមន៍ពីសំណាក់បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចស្នើភាគីទាំងអស់ឱ្យបន្តការចរចាដោយសុទ្ធចិត្ត ដើម្បីស្វែងរកដំណោះស្រាយ។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវអនុវត្តតាមនីតិវិធីដែលបានបោះពុម្ពផ្សាយរួចហើយអំពីការដោះស្រាយវិវាទនៅពេលធ្វើអន្តរាគមន៍។

ភាគីទាំងអស់ត្រូវទទួលខុសត្រូវក្នុងការបង្ហាញភាពពិតតាមរយៈពាក្យស្នើសុំអន្តរាគមន៍ជាលាយលក្ខណ៍អក្សរដើម្បីគាំទ្រការទាមទាររបស់ខ្លួន។

បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសម្រេចដោះស្រាយវិវាទដោយផ្អែកលើភស្តុតាងដែលភាគីទាំងអស់បានប្រគល់ជូន ហើយត្រូវជម្រាបភាគីទាំងនោះវិញ មិនឱ្យលើសពី ៦០ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំជាលាយលក្ខណ៍អក្សរចុងក្រោយពីភាគីវិវាទ។

ល័ក្ខខ័ណ្ឌនៃដំណោះស្រាយវិវាទរបស់បញ្ញត្តិករទូរគមនាគមន៍ ឬ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់អំពីមូលហេតុឱ្យសមហេតុផល។

ផ្នែកទី ២

នីតិវិធីនៃការចរចាអំពីសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍

ប្រការ ១០ : ទសាលភាព និង កម្មវត្ថុនៃការអនុវត្ត

១) កំណត់អំពីការអនុវត្តការតភ្ជាប់បណ្តាញសំដៅជានាទូវចំណុះ ល្បឿន គុណភាព និង ថេរវេលាតភ្ជាប់ (ហៅកាត់ថា ការជាជាសមត្ថភាពតភ្ជាប់)។

២) ត្រូវអនុវត្តចំពោះរាល់ការចាត់ចែងលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់រវាងបណ្តាញទូរគមនាគមន៍សាធារណៈដូចខាងក្រោម៖

- បណ្តាញទូរគមនាគមន៍អចល័ត (ខេត្ត-ក្រុង ផ្លូវឆ្ងាយឆ្លងខេត្ត ឬ តំបន់ និងក្រៅប្រទេស),
- បណ្តាញទូរគមនាគមន៍ចល័ត (ទូទាំងប្រទេស និង ក្រៅប្រទេស)។

៣) មុខសញ្ញាត្រូវអនុវត្ត : គ្រប់ក្រុមហ៊ុនកាន់អាជ្ញាប័ណ្ណ ឬ មានអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រការ ១១ : គោលការណ៍នៃការតភ្ជាប់បណ្តាញរវាងគ្នា

១) ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវលើការកសាងផែនការ និងស្ថាបនាបណ្តាញទូរគមនាគមន៍ដោយមានប្រព័ន្ធត្រៀមបម្រុង សម្រាប់ធានាឆ្លើយតបនូវសមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈឱ្យបានគ្រប់គ្រាន់

ស្របតាមផែនការមេស្តីពីការអភិវឌ្ឍបណ្តាញនិងសេវាទូរគមនាគមន៍ ហើយទទួលខុសត្រូវលើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់។

២) ដោយអនុលោមតាមបទប្បញ្ញត្តិ និង ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនទូរគមនាគមន៍ បន្ទាប់ពីចុះបញ្ជីនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រៀងរាល់ឆ្នាំក្រុមហ៊ុនត្រូវចរចាគ្នា និង ចុះកិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈ (ហៅកាត់ថា **កិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់**) សម្រាប់អនុវត្តការតភ្ជាប់បណ្តាញ និង ផ្តល់សេវាទូរគមនាគមន៍នៅឆ្នាំបន្ទាប់។

៣) នៅពេលអនុវត្តការតភ្ជាប់បណ្តាញទូរគមនាគមន៍សាធារណៈ ក្រុមហ៊ុនទូរគមនាគមន៍ត្រូវទទួលខុសត្រូវធានានូវសមត្ថភាពតភ្ជាប់ទៅតាមផែនការដែលបានព្រមព្រៀងគ្នា ហើយធានាពុំរើសអើងការតភ្ជាប់ផ្ទៃក្នុងនិងខ្សែប្រព័ន្ធឡើយ។

៤) របាយការណ៍និងការដោះស្រាយវិវាទនៃការតភ្ជាប់រវាងក្រុមហ៊ុនដែលចូលរួមការតភ្ជាប់ ត្រូវអនុវត្តតាមប្រកាសនេះ និង ប្រកាសពាក់ព័ន្ធផ្សេងៗទៀត។

ប្រការ ១២ : ផែនការសមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នា

រៀងរាល់ឆ្នាំក្រុមហ៊ុនដែលស្នើសុំការតភ្ជាប់ត្រូវកសាងផែនការសមត្ថភាពតភ្ជាប់របស់ខ្លួនសម្រាប់មួយឆ្នាំបន្ទាប់ ហើយត្រូវផ្ញើទៅក្រុមហ៊ុនផ្តល់ការតភ្ជាប់ មុនថ្ងៃទី ៣០ខែធ្នូ រៀងរាល់ឆ្នាំ ដើម្បីឱ្យក្រុមហ៊ុនផ្តល់ការតភ្ជាប់មានមូលដ្ឋានធ្វើផែនការវិនិយោគបម្រើការងារតភ្ជាប់។ នៅក្នុងផែនការសមត្ថភាពតភ្ជាប់ប្រចាំឆ្នាំត្រូវបញ្ជាក់ច្បាស់អំពីពេលវេលា សមត្ថភាពប្រើប្រាស់ដោយលម្អិតតាមខែ ត្រីមាសចំពោះទិសដៅតភ្ជាប់នីមួយៗ និង ទីតាំងតភ្ជាប់។

ចំពោះវិធីសាស្ត្រគណនាសមត្ថភាពសរុបនៃការតភ្ជាប់មានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៤។

ប្រការ ១៣ : កិច្ចសន្យាស្តីពីការផ្តល់សមត្ថភាពតភ្ជាប់បណ្តាញរវាងគ្នា

១) កិច្ចសន្យាផ្តល់សមត្ថភាពតភ្ជាប់តម្រូវឱ្យក្រុមហ៊ុនពីរចរចាគ្នា និង ចុះកិច្ចព្រមព្រៀងរៀងរាល់ឆ្នាំតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីកិច្ចសន្យា។ កិច្ចសន្យានេះជាមូលដ្ឋានសម្រាប់អនុវត្តការតភ្ជាប់បណ្តាញទូរគមនាគមន៍រវាងក្រុមហ៊ុនពីរ។ ក្រៅពី

